ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
<u>នាយកដ្ឋានព័ត៌មាន</u>

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅប្រទេសហុងគ្រី និងការអញ្ជើញចូលរួមសន្និសីទកំពូលលើកទី៥ ស្តីពីអន្តរសកម្មភាព និងវិធានការកសាងទំនុកចិត្តនៅអាស៊ី នៅប្រទេសតាជីគីស្ថាន ពីថ្ងៃទី១៣ ដល់ទី១៥ ខែមិថុនា ឆ្នាំ២០១៩

=====

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ចប់ដោយជោគជ័យនូវដំណើរបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋហុងគ្រី និងការអញ្ជើញចូលរួមសន្និសីទកំពូលលើកទី៥ ស្តីពីអន្តរសកម្មភាពនិងវិធានការកសាងទំនុកចិត្តនៅអាស៊ី (CICA) នៅប្រទេសតាជីគីស្ថាន ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩។

I. <u>ទស្សនកិច្ចផ្លូវការរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី នៅសាធារណរដ្ឋហុងគ្រី</u>៖ ឯកសារនៃកិច្ចសហប្រតិបត្តិការចំនួន៤ ត្រូវបានចុះហត្ថលេខា ហើយស្ថានទូតនឹងត្រូវបើកដំណើរការឡើងវិញនៅទីក្រុងប៊ុយដាប៉េស និងក្រុងភ្នំពេញ

ក្នុងអំឡុងទស្សនកិច្ចនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានជួបពិភាក្សាទ្វេភាគីជាមួយឯកឧត្តម វិកទ័រ អ័របាន នាយករដ្ឋមន្ត្រីហុងគ្រី ក្នុងបរិយាកាសកក់ក្តៅ និងរីករាយ និងទទួលបានលទ្ធផលជាផ្លែផ្កា។ លើសពីនេះទៀត សម្តេចតេជោ បានជួបសំដែងការគួរសមដាច់ដោយឡែកពីគ្នា ជាមួយឯកឧត្តម យ៉ាណូស អាឌ័រ ប្រធានាធិបតីហុងគ្រី និង ឯកឧត្តម ឡាហ្សឡូ គ័វៀរ ប្រធានរដ្ឋសភាហុងគ្រី។



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

នាយករដ្ឋមន្ត្រីទាំងពីរ បានផ្លាស់ប្តូរទស្សនៈគ្នាទៅលើរបៀបវារៈទ្វេភាគី តំបន់ និងអន្តរជាតិ ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក។ ថ្នាក់ដឹកនាំទាំងពីរ បានផ្តល់សារៈសំខាន់ដល់ការជម្រុញកិច្ចសហប្រតិបត្តិការទ្វេភាគី និងខិតខំបង្កើនសក្តានុពលពាណិជ្ជកម្ម និងវិនិយោគ រវាងប្រទេសទាំងពីរឲ្យដល់កម្រិតអតិបរមា។ នាយករដ្ឋមន្ត្រីទាំងពីរ បានឯកភាពប្រគល់ភារកិច្ចជូនស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ ដើម្បីរៀបចំកិច្ចប្រជុំលើកទី១នៃគណៈកម្មការសេដ្ឋកិច្ចចម្រុះឲ្យបានឆាប់ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។

ថ្នាក់ដឹកនាំទាំងពីរ ក៏បានគូសបញ្ជាក់ផងដែរពីតួនាទីសំខាន់នៃវិស័យឯកជននៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងបានជម្រុញឲ្យមានកិច្ចសហការជិតស្និទ្ធរវាងសភាពាណិជ្ជកម្មកម្ពុជា និងហុងគ្រី ដើម្បីស្វែងរកសក្តានុពលសេដ្ឋកិច្ច និងកាលានុវត្តភាពធុរកិច្ចនៃប្រទេសទាំងពីរ។

ក្នុងនាមប្រជាជននិងរាជរដ្ឋាភិបាលកម្ពុជា **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានសម្តែងនូវការដឹងគុណចំពោះជំនួយរបស់ប្រជាជននិងរដ្ឋាភិបាលហុងគ្រី ដល់ប្រទេសកម្ពុជាក្នុងគ្រាដ៏លំបាកបំផុត បន្ទាប់ពីការរំដោះប្រទេសនៅឆ្នាំ១៩៧៩ និងការរួមចំណែករបស់ហុងគ្រី ដល់ប្រតិបត្តិការថែរក្សាសន្តិភាពរបស់អ៊ុនតាក់ និងការបន្តគាំទ្ររបស់ហុងគ្រីសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានសំដែងនូវការវាយតំលៃខ្ពស់ផងដែរចំពោះការគាំទ្ររបស់ហុងគ្រីលើគម្រោង **តេជោ** ភូមិ១០០ ការពិចារណាក្នុងការជួសជុលប្រាសាទកោះកេរ្តិ៍ និងសកម្មភាពកម្ចាត់មីននៅកម្ពុជា។ សម្តេចតេជោ ក៏បានថ្លែងអំណរគុណដ៏ស្មោះចំពោះរដ្ឋាភិបាលហុងគ្រី ដែលនឹងផ្តល់អាហារូបករណ៍ចំនួន១៥កន្លែងក្នុង១ឆ្នាំដល់និស្សិតកម្ពុជា នៅក្នុងក្របខណ្ឌនៃកម្មវិធីផ្លាស់ប្តូរវិស័យអប់រំ ឆ្នាំ២០២០ ដល់ឆ្នាំ២០២២។

ភាគីទាំងពីរ បានឯកភាពលើកកំពស់ការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការ រវាងរដ្ឋាភិបាល ស្ថាប័ននីតិបញ្ញត្តិ តុលាការ និងគណបក្សនយោបាយនៃប្រទេសទាំងពីរ។ បន្ថែមលើនេះទៀត កម្ពុជាត្រៀមនឹងរៀបចំកិច្ចពិគ្រោះយោបល់ទ្វេភាគីលើកទី២ រវាងក្រសួងការបរទេសទាំងពីរនៅឆ្នាំ២០២០។

ភាគីទាំងពីរ បានឯកភាពបើកដំណើរការឡើងវិញនូវស្ថានទូតរៀងៗខ្លួនប្រចាំរដ្ឋធានីប៊ុយដាប៉េស និងរាជធានីភ្នំពេញ ដើម្បីខួបខួប៦៥ឆ្នាំនៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងហុងគ្រី នៅឆ្នាំ២០២១ ខាងមុខ។

ឯកឧត្តម នាយករដ្ឋមន្ត្រី វីកទ័រ អ័របាន បានអះអាងជាថ្មីនូវជំហររឹងមាំរបស់ហុងគ្រី ប្រឆាំងនឹងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអរគុណហុងគ្រី ដែលតែងតែផ្តល់យុត្តិធម៌ដល់កម្ពុជា បើទោះជាគណៈកម្មការអឺរ៉ុប បានចាប់ផ្តើមដំណើរការនីតិវិធីសម្រាប់ការដកជាបណ្តោះអាសន្ននូវប្រព័ន្ធអនុគ្រោះពន្ធ EBA ក៏ដោយ។ ការគាំទ្រនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់កម្ពុជា ក្នុងការបន្តថែរក្សានិងការពារសន្តិភាព អធិបតេយ្យភាព និងឯករាជ្យជាតិ។

ថ្នាក់ដឹកនាំទាំងពីរ បានសម្តែងការគាំទ្រជាគោលការណ៍ចំពោះការតម្លើងទំនាក់ទំនងអាស៊ាន-សហភាពអឺរ៉ុប ទៅដល់កម្រិតដៃគូយុទ្ធសាស្ត្រ និង ចំពោះកិច្ចប្រឹងប្រែងសំដៅជំរុញឲ្យមានការចាប់ផ្តើមឡើងវិញនូវកិច្ចចរចាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-សហភាពអឺរ៉ុប (ASEAN-EU FTA)។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជម្រាបសមភាគីហុងគ្រីថា **សម្តេចនឹងដឹកនាំគណៈប្រតិភូ**ជាន់ខ្ពស់ អញ្ជើញចូលរួមកិច្ចប្រជុំកំពូលស្តីពីទឹកលើកទីបី ឆ្នាំ២០១៩ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងប៊ុយដាប៉េស នាខែតុលាខាងមុខនេះ។

ចំណែកឯ ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងគណបក្សកាន់អំណាចវិញ នាយករដ្ឋមន្ត្រីទាំងពីរ ក្នុងឋានៈជាប្រធានគណបក្សរៀងៗខ្លួន បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នារវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសម្ព័ន្ធភាពពលរដ្ឋហុងគ្រី-ហ្វីដេស (FIDESZ) នៃប្រទេសហុងគ្រី។

នៅមុនជំនួបពេញអង្គរបស់នាយករដ្ឋមន្ត្រីទាំងពីរ ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានជួបសមភាគីហុងគ្រី ឯកឧត្តម **ផេធ័រ ហ្ស៊ីយ៉ាតូ** ដើម្បីផ្លាស់ប្តូរទស្សនៈលើបញ្ហាទ្វេភាគី តំបន់ និងពហុភាគី ដែលជាការចាប់អារម្មណ៍រួម។ នៅចុងបញ្ចប់នៃជំនួបនេះ ឯកសារនៃកិច្ចសហប្រតិបត្តិការចំនួន៣ ត្រូវបានចុះហត្ថលេខា ដែលរួមមាន៖

១. អនុស្សរណៈយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ រវាងទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេសនិងពាណិជ្ជកម្មហុងគ្រី

២. អនុស្សរណៈយោគយល់ស្តីពីកម្មវិធីផ្លាស់ប្តូរវិស័យអប់រំ សម្រាប់ឆ្នាំ២០២០ ដល់ឆ្នាំ២០២២ រវាងក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងធនធានមនុស្សហុងគ្រី និង

៣. កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសហុងគ្រី។

**II. <u>ការអញ្ជើញចូលរួមរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី នៅក្នុងសន្និសីទកំពូល CICA លើកទី៥ នៅទីក្រុងឌូសានបេ ប្រទេសតាជីគីស្ថាន</u>៖ ជំនួបទ្វេភាគីជាមួយប្រធានាធិបតីតាជីគីស្ថាន គីជីស្ថាន និងតួកគី**

នៅក្នុងសន្និសីទកំពូល CICAលើកទី៥នេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងសុន្ទរកថា ដោយសង្កត់ធ្ងន់ថា ការអភិវឌ្ឍនិងភាពរុងរឿង ពិតជាមិនអាចកើតមានជាដាច់ខាត ប្រសិនបើគ្មានសន្តិភាព និងសន្តិសុខជារួមនោះទេ។ ហើយប្រសិនបើគ្មានសន្តិភាពនិងសន្តិសុខ យើងក៏នឹងមិនអាចបំពេញបាននូវការសន្យារបស់យើងចំពោះរបៀបវារៈសកលរបស់អង្គការសហប្រជាជាតិឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពបានឡើយ។

លើសពីនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍ថា កម្ពុជាមានបំណងស្វែងរកកាលានុវត្តភាពពាណិជ្ជកម្មនិងការវិនិយោគបន្ថែមទៀត ជាមួយប្រទេសជាសមាជិករបស់CICA ទាំងអស់។ យើងគួរធ្វើការកាន់តែជិតស្និទ្ធជាមួយនឹង «គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ» ដែលជាក់ស្តែងនឹងផ្តល់ឱកាសដ៏ល្អសម្រាប់ប្រទេសជាសមាជិក CICA ដើម្បីពន្លឿនការតភ្ជាប់តំបន់ និងពង្រឹងប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក។

ថ្នាក់ដឹកនាំនៃសន្និសីទកំពូល CICAលើកទី៥ បានចេញសេចក្តីថ្លែងការណ៍មួយ ដែលក្នុងនោះបានគាំទ្រទាំងស្រុង នូវគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងឬខាងក្រៅរបស់រដ្ឋដទៃ។ ថ្នាក់ដឹកនាំអះអាងយ៉ាងមុតមាំថា គ្មានរដ្ឋណាមួយ ឬរដ្ឋជាក្រុម មានសិទ្ធិធ្វើអន្តរាគមន៍ ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី និងក្រោមហេតុផលណាក៏ដោយ ទៅក្នុងកិច្ចការផ្ទៃក្នុងឬខាងក្រៅ របស់រដ្ឋណាមួយផ្សេងទៀតឡើយ ដែលរួមមានទាំងគោលបំណងផ្លាស់ប្តូររដ្ឋាភិបាលស្របច្បាប់។ថ្នាក់ដឹកនាំក៏បានបញ្ជាក់ថារដ្ឋនីមួយៗមានសិទ្ធិកំណត់ប្រព័ន្ធនយោបាយរៀងៗខ្លួន។

ក្នុងអំឡុងពេលសន្និសីទកំពូលនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាដាច់ដោយឡែកពីគ្នា ជាមួយឯកឧត្តម **អ៊ីម៉ូម៉ាលី រ៉ាសម៉ុន** (Emomali Rahmon) ប្រធានាធិបតីតាជីគីស្ថាន ឯកឧត្តម **ស៊ូរ៉ុនបាយ ជីនបេកូវ** (Sooronbay Jeenbekov) ប្រធានាធិបតីគីជីស្ថាន និងឯកឧត្តម **រ៉េជិប ថាយយ៉ិប អែរដូហ្គាន់** (Recep Tayyip Erdoğn) ប្រធានាធិបតីតួកគី។ រាល់ការពិភាក្សាទាំងអស់ផ្តោតជុំវិញការពង្រឹងទំនុកចិត្តនយោបាយ និងការលើកកំពស់កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដែលមានចាប់ពីវិស័យពាណិជ្ជកម្មនិងវិនិយោគ ទៅដល់ការជម្រុញវិស័យវប្បធម៌និងទេសចរណ៍។

ថ្ងៃពុធ ២ រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៩